ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# តាមនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណី

លេខ ១៩៥៨

ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១.

សាលក្រមរដ្ឋប្បវេណី

លេខ ០៤ ក្រ២ "ណ"

ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១២

បានបញ្ចប់ការទាញហេតុផលផ្ទាល់មាត់ នៅថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១២ លើសំណុំរឿងរដ្ឋប្បវេណីលេខ ១៩៥៨ ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១ ដែលមានសមាសភាពដូចតទៅ ៖

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះសាលាដំបូងរាជធានីភ្នំពេញ

**ចៅក្រមប្រឹក្សា**

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

-រាំងដើមចោទឈ្មោះ [redacted] **ខវីនី** ភេទស្រី អាយុ ៤២ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ រកស៊ី មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ១២៣ AE0 ផ្លូវលេខ ២២៨ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

*មេធាវីតំណាងដោយអាណត្តិលោក* [redacted]

-ចុងចម្លើយឈ្មោះ [redacted] **សុភាព** ភេទស្រី អាយុ ៣៩ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ មន្ត្រីរាជការ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ៧៣ E0 ផ្លូវលេខ ២០០៤ ក្រុមទី ១៤ សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] មុំ ( ស្លាប់ ) ម្តាយឈ្មោះ [redacted] មុក ( ស្លាប់ ) ប្តីឈ្មោះ [redacted] ស្រាយ មានកូន ០២ នាក់ ។

*មេធាវីតំណាងដោយអាណត្តិលោក* [redacted]

**កម្មវត្ថុបណ្តឹង** : *ប្តឹងសុំទាមទារប្រាក់ជំពាក់ពីឈ្មោះ* [redacted] *សុភាព*

**អង្គហេតុ និង ចំណុចខាងច្បាប់**

*១-សាលក្រមទាមទារដោយដើមចោទ*

ក-សុំរំលាយកិច្ចសន្យាជួលផ្ទះ ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១០ ។

ខ-សុំឲ្យឈ្មោះ [redacted] សុភាព បង់ប្រាក់ ១២០០.០០០រៀល ( មួយលានពីរសែនរៀល ) ក្នុង១ថ្ងៃ គិតចាប់ពីថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ ។

គ-ទាមទារថ្លៃចាក់ដី ធ្វើដំបូលនិងថ្លៃទទឹក ៥១៦៣៥$ (ប្រាំបួនម៉ឺនមួយពាន់ប្រាំមួយរយសាមសិបប្រាំដុល្លាអាមេរិក)។

ឃ-ទាមទារប្រាក់កក់ចំនួន ៤៨០០ $ ( បួនពាន់ប្រាំបីរយដុល្លារអាមេរិក ) × ៣ មកកូនក្តីខ្លួនឈ្មោះ [redacted] រ៉ានី តាមកិច្ចសន្យា ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១០ ។

ង-សងជម្ងឺចិត្ត ការខាតបង់ពេលវេលា ការចំណាយផ្សេងៗ រួមទាំងចំណាយសេវាមេធាវីជាប្រាក់ចំនួន ១០០.០០០$ ( ដប់ម៉ឺនដុល្លាអាមេរិក ) ។

ច-សុំឲ្យតុលាការប្រកាសថា សាលក្រមនេះអនុវត្តជាបណ្តោះអាសន្នបាន ។

ឆ-ប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់ចុងចម្លើយ ។

២- *ការអះអាងរបស់គូភាគី*

*ក-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទឈ្មោះ [redacted] រ៉ានី បាន ថ្លែងការណ៍ថា* : ខ្លួនជាមេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ [redacted] រ៉ានី ខ្លួនប្តឹងសុំរំលាយកិច្ចសន្យា ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១០ ដែលកូនក្តីខ្លួនបានជួលផ្ទះពីឈ្មោះ [redacted] សុភាព មានរយៈពេល ០៥ឆ្នាំ ។ ការជួលផ្ទះនេះក្នុងមួយខែតម្លៃ ៤០០ $ តែមិនទាន់អនុវត្តនូវកិច្ចសន្យាចប់ផង ស្រាប់តែអ្នកស្រី កែវ សុភាព បានផ្តាច់ភ្លើង និងទឹកមិនឲ្យកូនក្តីខ្លួនប្រកបអាជីវកម្មឡើយ ។ ក្រោយពីបានជួលផ្ទះ កូនក្តីខ្លួនបានធ្វើការជួសជុលកែលំអផ្ទះ ដូចជាជួសជុល សាងសង់ ចាក់ដី ធ្វើដំបូល ទទឹក ទិញសម្ភារៈផ្សេងៗសម្រាប់ធ្វើអាជីវកម្ម សំអាងការ កាត់សក់ បុរសនារី និងចំណាយលើសម្ភារៈលក់អាហារពេលយប់ អស់ប្រាក់ចំនួន ៥១៦៣៥ $ ។ ការផ្តាច់ចរន្តអគ្គីសនីនេះធ្វើឲ្យមានការរស់នៅនិងការប្រកបអាជីវកម្មជួបការលំបាកជាខ្លាំង ព្រោះថា ឧបករណ៍អាជីវកម្មរបស់កូនក្តីខ្លួនគឺដំណើរការបានដោយសារមានថាមពលអគ្គីសនី បើគ្មានអគ្គីសនីទេអាជីវកម្មរបស់កូនក្តីខ្លួនឈប់ដំណើរការ គឺបាត់ចំណូលក្នុងមួយថ្ងៃចំនួន ១.២០០.០០០រៀល ( មួយលានពីរសែនរៀល ) ។ ការជួលផ្ទះនេះគឺកូនក្តីខ្លួនជួលដើម្បីស្នាក់នៅនិងប្រកបអាជីវកម្មមានដូចជា កាត់សក់ , អ៊ុតសក់ ,ធ្វើសក់ ,លក់គ្រឿងសំអាងនៅពេលថ្ងៃ និងលក់បាយឆា , មីឆា , គុយទាវឆា និងបបរសនៅពេលយប់ ។ ក្នុងកិច្ចសន្យាត្រង់ប្រការ ៥ ចំណុច ៥,២ ដែលចែងថា ក្នុងរយៈពេលនៃកិច្ចសន្យាជួល ភាគី ( ក ) ( អ្នកស្រី [redacted] សុភាព ) សន្យាមិនត្រូវធ្វើអ្វីដែលបង្កការលំបាកដល់ការស្នាក់នៅ ឬប្រកបអាជីវកម្មស្របច្បាប់របស់ភាគី ( ខ ) ( លោកស្រី យឹម រ៉ានី ) នៅផ្ទះជួលនេះឡើយ លើកលែងតែករណី ភាគី ( ខ ) មិនបំពេញកាតព្វកិច្ចរបស់ខ្លួនដូចមានចែងក្នុងប្រការ ៣ នៃកិច្ចសន្យាជួលនេះ ។ ការជួលផ្ទះនេះបានជាច្រើនខែ ហើយចុងចម្លើយអ្នកស្រី [redacted] សុភាព បានផ្តាច់ភ្លើងនិងទឹកដោយលើកហេតុផលថា ខ្លួនមិនបានបង់ប្រាក់ឈ្នួលផ្ទះមួយខែនៅពេលជួលផ្ទះលើកដំបូង ការលើកឡើងនេះមិនសមហេតុផលទាល់តែសោះ ពីព្រោះខ្លួនបានបង់ប្រាក់ឈ្នួលផ្ទះជាទៀងរាល់ខែមិនដែលខាក់ខានឡើយ ព្រមទាំងក្នុងនោះក៏មានប្រាក់កក់សម្រាប់ធានាផងដែរ ។

*ខ-លោក មួង សុគន្ធ ជាមេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយឈ្មោះ [redacted] សុភាព បានថ្លែងការណ៍ថា* : កូនក្តីខ្លួនឈ្មោះ [redacted] សុភាព បានជួលផ្ទះឲ្យទៅឈ្មោះ [redacted] រ៉ានី ដោយបានធ្វើកិច្ចសន្យា ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០១០ ក្នុងមួយខែ ៤០០$ ហើយកិច្ចសន្យាផុតអាណត្តិនៅឆ្នាំ ២០១៥ ។ មូលហេតុនៃការសុំរំលាយកិច្ចសន្យា ដោយសារភាគីដើមចោទមិនបានបង់ប្រាក់ឈ្នួលផ្ទះមួយខែ ដូចមានចែងក្នុងប្រការ ៨.១ នៃកិច្ចសន្យា ដោយអញ្ជើញភាគីដើមចោទចូលមកដោះស្រាយតែភាគីដើមចោទពុំព្រមចូល ។ ប្រការ ៥.២ លើកលែងតែប្រការ ៣ ភាគីដើមចោទត្រូវបង់ប្រាក់ឈ្នួលផ្ទះ

ជារៀងរាល់ខែ តែភាគីដើមចោទមិនគោរពកិច្ចសន្យា ។ នៅក្នុងដំណាក់កាលត្រៀមសម្រាប់ការទាញហេតុផលលើកទី១ ដើមចោទបានសុំអោយកូនក្តីខ្លួនអនុវត្តនូវកិច្ចសន្យា រហូតដល់ដំណាក់កាលត្រៀមសម្រាប់ការទាញហេតុផលលើកទី២ទៀត នៅពេលនេះមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទបានកែប្រែកម្មវត្ថុ ដោយសុំរំលាយកិច្ចសន្យាទៅវិញ ។ នៅក្នុងកិច្ចសន្យាក្នុងប្រការ ៧ និងប្រការ ៣ ថា នៅពេលដែលភាគី ( ខ ) ដែលជាភាគីឈ្មោ[redacted] រីទី មិនបានបង់ថ្លៃផ្ទះហួសរយៈពេលកំណត់ ៣០ ថ្ងៃ ភាគី ( ក ) ដែលជាកូនក្តីខ្លួនមានសិទ្ធិសុំផ្អាកការស្នាក់នៅ ឬធ្វើអាជីវកម្មជាបណ្តោះអាសន្ន ។ ក្នុងរឿងនេះភាគី ( ខ ) ដែលជាអ្នកជួលផ្ទះកូនក្តីខ្លួន ឈ្មោះ[redacted] សុភាព មិនបានអនុវត្តនូវកិច្ចសន្យាដោយមិនបានបង់ប្រាក់ថ្លៃឈ្នួលផ្ទះ ហើយកូនក្តីខ្លួនបានព្យាយាមហៅភាគី ( ខ )ឈ្មោះ[redacted] រីទី មកដោះស្រាយ តែភាគី ( ខ )មិនបានចូលមកដោះស្រាយឡើយ ទើបកូនក្តីខ្លួនផ្តាច់ទឹកនិងចរន្តអគ្គិសនី ហើយចរន្តអគ្គីសនីនេះ គឺកូនក្តីខ្លួនជាអ្នកទិញ ដូច្នេះកូនក្តីខ្លួនមានសិទ្ធិហៅបុគ្គលិកអគ្គីសនីមកផ្តាច់ រីឯឈ្មោះ[redacted] រីទី បានតភ្លើងពីផ្ទះអ្នកជិតខាងមកប្រើប្រាស់ ដោយមិនបានឆ្លងកាត់កូនក្តីខ្លួនជាម្ចាស់ផ្ទះ ទើបកូនក្តីខ្លួនផ្តាច់ចោលនូវខ្សែភ្លើងនោះចេញ ។

-ការទាមទាររបស់មេធាវីតំណាងអោយដើមចោទ សុំទាមទារក្នុងមួយថ្ងៃចំនួន ១.២០០.០០០រ ( មួយលានពីរសែនរៀល ) ពីកូនក្តីខ្លួននោះ ខ្លួនមិនអាចសងបាននោះទេ រីឯការទាមទារថ្លៃជួសជុលផ្ទះចំនួន ៥១៦៣៥ $ នេះជាទូរលេខខ្យល់ ពុំមាននោះទេ ព្រោះបើដើមចោទមានប្រាក់ចំនួន ៥១៦៣៥ $ នោះដើមចោទប្រាកដជាទៅទិញផ្ទះល្វែងថ្មីបើកធ្វើអាជីវកម្មដោយខ្លួនឯង មិនបាច់ជួលទេ ។ ការជួសជុលផ្ទះប្រក់ ដំបូល ចាក់ដី និងដាក់ទុទឹកដែលធ្វើរបាយការណ៍ដាក់ជូនតុលាការនេះពុំត្រឹមត្រូវទេ គ្មានអាជ្ញាធរណាទទួលស្គាល់ទេ គឺបុគ្គលជាអ្នកធ្វើតែឯងៗ ខ្លួនសូមឲ្យតុលាការច្រានចោល ការទាមទារនេះកូនក្តីខ្លួនមិនអាចសងបាននោះទេ ។

-ការទាមទារឲ្យចេញសងចំណាយមេធាវី និងចំណាយទៅលើបុគ្គលិកប្រចាំក្នុងហាងចំនួន ១០ម៉ឺនដុល្លាអាមេរិក នេះកូនក្តីខ្លួនមានលទ្ធភាពសងនោះទេ ពីព្រោះថា តើដើមចោទខូចខាតលើអ្វីខ្លះ ? ចំណែកលោកមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទសុំឲ្យតុលាការប្រកាសសាលក្រមអនុវត្តបណ្តោះអាសន្នពុំត្រឹមត្រូវនោះទេ ព្រោះកូនក្តីខ្លួននៅតែអនុវត្តកិច្ចសន្យាដដែល មិនមែនកូនក្តីខ្លួនមិនគោរពកិច្ចសន្យាទេ គឺភាគីអ្នកជួលទេដែលមានកំហុស ។ ចំពោះប្រាក់ប្រដាប់ក្តីត្រូវឲ្យដើមចោទជាអ្នកទទួលរាប់រងប្រាក់ប្រដាប់ក្តីពីព្រោះកូនក្តីខ្លួនគ្មានកំហុស ។ រីឯប្រាក់កក់ចំនួន ៤៨០០ $ ( បួនពាន់ប្រាំបីរយដុល្លាអាមេរិក) ដែលភាគីអ្នកជួលបានកក់ប្រាក់ឲ្យកូនក្តីខ្លួននេះ មិនមែនសម្រាប់យកមកទូទាត់ថ្លៃទឹកនិងភ្លើងនោះទេគឺនៅក្នុងកិច្ចសន្យាចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០១០ ត្រង់ប្រការ ៦ និងប្រការ ២ ក្នុងករណីដែលភាគី ( ខ ) បានបញ្ឈប់កិច្ចសន្យានេះមុនកំណត់ដូចមានចែងក្នុងប្រការ២ ខាងលើ ប្រាក់កក់តម្កល់នេះត្រូវបានជាប្រយោជន៍ដល់ភាគី ( ក ) ផ្ទុយទៅវិញលើភាគី ( ក ) បានបញ្ឈប់កិច្ចសន្យាជួលនេះមុនកំណត់វិញនោះភាគី ( ក ) ត្រូវសងទៅឲ្យភាគី( ខ )វិញ ស្មើនឹងប្រាក់កក់១២ខែ គុណនឹងបីដង។ សំណូមពរសុំរំលាយកិច្ចសន្យា ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១០ និងច្រានចោលការទាមទាររបស់ដើមចោទ ។

-សាក្សីឈ្មោះ[redacted]សុខខែម ជាសាក្សីខាងភាគីដើមចោទ បានថ្លែងការណ៍ថា : ខ្លួនជាក្មួយបង្កើតរបស់ឈ្មោះ[redacted] រីទី ហើយខ្លួនជាអ្នកទទួលប្រាក់ថ្លៃលក់ផលិតផល កាត់សក់បុរសនារី និងប្រាក់លក់បបរ , មី , គុយទាវ ដែលខ្លួនជាអ្នកទទួលប្រាក់ផ្ទាល់ ។ ចំពោះផ្នែកកាត់សក់បុរស គឺមានកាត់សក់ធម្មតា និងមានកាត់ជា VIP កាត់ក្រចក សំអាតត្រចៀក ត្រាំទឹកដោះគោ ម៉ាស្សាមុខ ។ ផ្នែកកាត់សក់នារី គឺមានកាត់ក្រចក ត្រាំទឹកដោះគោ ម៉ាស្សាមុខ ។ ផ្នែកអាហារដ្ឋាន មានលក់បបរ , មីឆា , បាយ , គុយទាវ ។ ការកាត់សក់ផ្នែកបុរសនារី និងលក់ផលិតផល ក្នុងមួយថ្ងៃបានប្រាក់ចំណូលប្រហែល ៨០ម៉ឺនរៀល តែខ្លួនគ្មានបញ្ជីកត់ត្រានោះទេ គឺរាប់លុយឲ្យមីងរបស់ខ្លួនឈ្មោះយឹម រីទី ផ្ទាល់តែម្តង នៅម៉ោង ៧ល្ងាច ។ ខ្លួនបានចូលបំពេញការងារនៅទីនោះចាប់ពីមីងរបស់ខ្លួនបានបើកហាងជាលើកដំបូងម្ល៉េះ ហើយខ្លួនមានតួនាទីទទួលប្រាក់ខែ២០០$ មានបុគ្គលិក ចំនួន ២០ នាក់ ។ ក្រៅពីនេះខ្លួនពុំដឹងពីការឈ្លោះគ្នារវាងមីងឈ្មោះ[redacted] រីទី និងម្ចាស់ផ្ទះឈ្មោះ[redacted]សុភាព នោះទេ ។ នៅពេលបិទហាងខ្លួនមកស្នាក់នៅផ្ទះរបស់មីងជួយមើលការខុសត្រូវសម្ភារះនៅក្នុងហាងទាំងអស់ ។

-មេធាវីលោក[redacted] បានធ្វើសេចក្តីសន្និដ្ឋានថា : មេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយបានទទួលស្គាល់ថា ពិតជាបានចុះកិច្ចសន្យាជាមួយកូនក្តីខ្លួនឈ្មោះ[redacted] រីទី ដែលជាអ្នកជួលផ្ទះ ហើយបានទុករយៈពេល ២០ ថ្ងៃ

ដើម្បីឲ្យកូនក្តីខ្លួនជួសជុលផ្ទះ ដែលការជួសជុលនេះអស់ប្រាក់ចំនួន ៩១៦៣៥$ ហើយម្ចាស់ផ្ទះបានផ្តាច់ភ្លើងធ្វើឲ្យអាជីវកម្មរបស់កូនក្តីខ្លួនត្រូវបានបិទ ដែលនាំឲ្យផលិតផលដែលបំពាក់នៅក្នុងហាងត្រូវខូចខាតទាំងស្រុង។ ដូច្នេះខ្លួនស្នើសុំឲ្យតុលាការចេញសាលក្រមទៅតាមការប្តឹងសុំរបស់កូនក្តីខ្លួនខាងលើ ដោយក្តីអនុគ្រោះ ។

-មេធាវីលោក [redacted] បានធ្វើសេចក្តីសន្និដ្ឋានថា : កិច្ចសន្យា គឺផ្អែកទៅតាមច្បាប់ គូភាគីត្រូវអនុវត្តឲ្យបានត្រឹមត្រូវ តែពេលនេះបើភាគីអ្នកជួលចង់រំលាយនូវកិច្ចសន្យា ភាគីខាងខ្លួនក៏ឯកភាពដែរក្នុងការរំលាយកិច្ចសន្យាចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១០ តែសូមឲ្យតុលាការពិនិត្យមើលថា កូនក្តីខ្លួនមានកំហុស រឺភាគីអ្នកជួលមានកំហុស ។ រីឯសាក្សីដែលបានចូលមកឆ្លើយនាពេលសវនាការពុំទាន់បានស្បថនោះទេ តែខ្លួនក៏មិនបដិសេធដែរ ។ ចំណែកការទទួលប្រាក់បានពីចំណូលនោះគឺសាក្សីបានរៀបរាប់តែពីចំណូលថា បានចំនួន ៨០ម៉ឺនរៀល រីឯការអះអាងរបស់ដើមចោទថា ចំណូលក្នុងមួយថ្ងៃបាន ១.២០០.០០០រៀល ( មួយលានពីរសែនរៀល ) ចំណុចនេះសុំឲ្យតុលាការពិនិត្យពិចារណា ។ ខ្លួនពុំបដិសេធការចាក់ដី តែអត់មានការចាក់ដីធំដុំ ធ្វើដំបូលផ្ទះអស់ប្រាក់ច្រើនសន្ធឹកសន្ធាប់នោះឡើយ ។ ផ្ទះនោះគឺជាប្រភេទផ្ទះល្វែងតូច ដូច្នេះមិនអាចមានចំណូលខ្ពស់ទេ ។ សំណូមពរសុំរំលាយកិច្ចសន្យា និងច្រានចោលការទាមទាររបស់ដើមចោទ ។

*៣- ការពន្យល់ត្រួសៗអំពីរឿងក្តី*

*-អង្គហេតុដែលជាមូលហេតុនៃការទាមទារ .*

តាមពាក្យបណ្តឹង ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ និងពាក្យបណ្តឹងបន្ថែម ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១២ លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទឈ្មោះ [redacted] វីនី បានអះអាងថា : កាលពីថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១០ ខ្លួនបានចុះកិច្ចសន្យាជួលផ្ទះរបស់ឈ្មោះ [redacted] សុភាព មួយកន្លែងដែលមានទីតាំងនៅផ្ទះលេខ ៧៣ E0 ផ្លូវលេខ ២០០៤ ភូមិតាងួន សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ ដើម្បីស្នាក់នៅនិងប្រកបមុខរបរអាជីវកម្មមាន កាត់សក់ អ៊ុតសក់ ធ្វើសក់ លក់គ្រឿងសំអាងនៅពេលថ្ងៃ និងលក់បាយឆា មីឆា គុយទាវឆា និងបបរសានៅពេលយប់ ។ កិច្ចសន្យានេះមានរយៈពេល ៥ឆ្នាំ ( ពីថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១០ ដល់ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៥ ) ដោយឯកភាពគ្នាក្នុងតម្លៃ ៤០០ $ ក្នុង១ខែ ។ ក្រោយពីបានចុះកិច្ចសន្យារួចឈ្មោះ [redacted] វីនី បានចំណាយប្រាក់អស់ចំនួន ២៣,០០០$ ក្នុងការជួសជុលកែលំអផ្ទះឲ្យសមរម្យទៅតាមការប្រកបមុខរបររបស់ខ្លួន ក្នុងនោះដែរភាគីម្ចាស់ផ្ទះតម្រូវអោយឈ្មោះ [redacted] វីនី ចេញសោហ៊ុយក្នុងការតភ្ជាប់បណ្តាញទឹកស្អាត និងអគ្គីសនីដោយខ្លួនឯង យឹម វីនី ក៏យល់ព្រម។ ក្រោយមក [redacted] វីនី បានប្រកបមុខរបររបស់ខ្លួនអស់រយៈពេល១ឆ្នាំ ស្រាប់តែនៅថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ វេលាម៉ោង ៩ និង ១៥នាទីព្រឹក មានមន្ត្រីអគ្គីសនីមកផ្តាច់ចរន្តអគ្គីសនីផ្ទះរបស់ឈ្មោះ [redacted] វីនី ក្រោយពីមានការសួរនាំរួចមក មន្ត្រីអគ្គីសនីនោះបានប្រាប់មូលហេតុថា គឺអ្នកស្រី កែវ សុភាព បានដាក់ពាក្យស្នើសុំផ្តាច់ចរន្តអគ្គីសនី ដែលឈ្មោះ [redacted] វីនី កំពុងប្រើប្រាស់និងបង់ថ្លៃប្រើប្រាស់ប្រចាំខែ ។ ការផ្តាច់ចរន្តអគ្គីសនីនេះបានធ្វើអោយការរស់នៅនិងការប្រកបអាជីវកម្មជួបការលំបាកជាខ្លាំង ព្រោះថាឧបករណ៍អាជីវកម្មរបស់ឈ្មោះ [redacted] វីនី គឺដំណើរការបាន ដោយសារតែមានថាមពលអគ្គីសនីបើគ្មានអគ្គីសនីទេអាជីវកម្មរបស់ [redacted] វីនី ត្រូវឈប់ដំណើរការ គឺបាត់ចំណូលមួយថ្ងៃ ១.២០០.០០០រៀល ( មួយលានពីរសែនរៀល ) ។ ឈ្មោះ [redacted] វីនី បានទាក់ទងឯកឧត្តម កែវ សុផល ត្រូវជាបងប្រុសបង្កើតរបស់ [redacted] សុភាព បន្ទាប់មកលោក [redacted] សំបូរ ជាតំណាងរបស់ [redacted] វីនី និងលោកមេភូមិតាងួនជួយនិយាយជាមួយម្ចាស់ផ្ទះអោយតភ្លើងអោយវិញ ប៉ុន្តែអ្នកស្រី [redacted] សុភាព មិនព្រមទទួលយកការដោះស្រាយឡើយ ។ មិនត្រឹមតែប៉ុណ្ណោះអ្នកស្រី [redacted] សុភាព បានពោលពាក្យខ្លាំងៗថា នឹងធ្វើយ៉ាងណាអោយការលក់ដូរប្រចាំរបស់ឈ្មោះ [redacted] វីនីទៅមុខមិនរួចឈប់ដំណើរការដោយគ្មានភ្លើង និងព្រមានបិទទឹកមិនអោយប្រើថែមទៀតផង ។ លុះមកដល់ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ [redacted] វីនី បានសំណូមពរទៅមន្ត្រីអគ្គីសនីដើម្បីជួយភ្ជាប់អោយខ្លួនមានចរន្តអគ្គីសនីប្រើប្រាស់ឡើងវិញ ។ មន្ត្រីអគ្គីសនីបានតបណ្តាញចេញពីផ្ទះអ្នកជិតខាង ដែលមានសណ្តានចិត្តល្អជួយផ្តល់ចរន្តអគ្គីសនីអោយ [redacted] វីនី ប្រើប្រាស់បានខ្លះៗជាបណ្តោះអាសន្ន ដោយ [redacted] វីនី ត្រូវចំណាយប្រាក់ជាច្រើនក្នុងការទិញខ្សែភ្លើង និងសម្ភារៈចាំបាច់មួយចំនួនទៀត ដើម្បីតបណ្តាញភ្លើងឡើងវិញ ។ នៅពេលតភ្ជាប់នោះ អ្នកស្រី [redacted] សុភាព បានពោលពាក្យព្រមានដល់ម្ចាស់ផ្ទះ និងមន្ត្រីអគ្គីសនីដែលបានអនុញ្ញាតតភ្លើងឲ្យ [redacted] វីនី ទៀតផង ។ នៅយប់ថ្ងៃដដែលនោះ វេលាម៉ោង ៧យប់ ស្រាប់តែ



Scanned with CamScanner

កន្លែងលក់ដូរបស់ឈ្មោះ[redacted] វីនី ដាច់ភ្លើង ហើយផ្ទះដែល[redacted] វីនី តភ្លើងយកមកប្រើនោះក៏ដាច់ភ្លើងដែរ ពេលនោះក៏មានការឆោឡោឡើងឮសំលេងគេស្រែកថាចោរៗ ហើយនាំគ្នាចាប់ចោរ ។ មន្ត្រីអគ្គិសនីបានថតរូបភាពអ្នកស្រី[redacted] សុភាព ពេលកំពុងនៅលើជណ្តើរឡើងបង្គោលភ្លើងទាញផ្តាច់ខ្សែចរន្តអគ្គិសនីដូចមានបង្ហាញក្នុងរូបថតស្រាប់ ។

ក្នុងនាម[redacted] វីនី ដែលជាអ្នកទទួលបាននូវសិទ្ធិរស់នៅ និងប្រកបអាជីវកម្មរយៈពេល៤ឆ្នាំទៀត តាមកិច្ចសន្យាជួលផ្ទះចុះថ្ងៃទី ១០-វិច្ឆិកា-២០១០[redacted] វីនី បានដាក់ពាក្យសុំទៅអាជ្ញាធរអគ្គិសនីដើម្បីតភ្ជាប់ចរន្តអគ្គិសនីឡើងវិញ ក្រោយមកនៅថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ មន្ត្រីអគ្គិសនីបានចុះមកដើម្បីតភ្ជាប់ចរន្តអគ្គិសនីជូន[redacted] វីនី ប៉ុន្តែអ្នកស្រី [redacted] សុភាព មកធ្វើការរារាំមិនឲ្យមន្ត្រីអគ្គិសនីធ្វើការតភ្ជាប់ចរន្តអគ្គិសនីឲ្យឈ្មោះ [redacted] វីនី ទេ ដោយប្រើពាក្យសម្តីខ្លាំងៗទៅលើមន្ត្រីអគ្គិសនីទាំងនោះ ។ សកម្មភាពរបស់អ្នកស្រី[redacted] សុភាព បានផ្ទុយនឹងគោលនយោបាយដឹកនាំរបស់រដ្ឋាភិបាល និងការដឹកនាំរបស់អាជ្ញាធររាជធានីភ្នំពេញ អាជ្ញាធរខណ្ឌ និងអាជ្ញាធរសង្កាត់ ដើម្បីស្វែងរកសេចក្តីសុខនិងការអភិវឌ្ឍន៍ជូនប្រជាពលរដ្ឋ។ នៅថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ ដោយសារទ្រាំមិនបាននឹងសម្តីអសារសរបស់អ្នកស្រី[redacted] សុភាព ម្ចាស់ផ្ទះដែលតភ្លើងឲ្យ[redacted] វីនី ប្រើបណ្តោះអាសន្ននោះក៏ផ្តាច់ភ្លើងឈប់អោយ[redacted] វីនី ប្រើតទៅទៀតដែរ ។

៤-ចំណុចវិវាទ

ក-កិច្ចសន្យាជួលផ្ទះ ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០១០ រវាងឈ្មោះ [redacted] សុភាព ជាភាគីម្ចាស់ផ្ទះ និងឈ្មោះ[redacted] វីនី ជាភាគីអ្នកជួលផ្ទះ តើភាគីណាមួយជាអ្នកមានកំហុស ?

ខ-ដើមចោទទាមទារឲ្យចុងចម្លើយសងការខូចខាតចំនួន ១.២០០.០០០រៀល ក្នុងមួយថ្ងៃ គិតពីថ្ងៃផ្តាច់ភ្លើង ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ រហូតមកដល់ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៥ , ទាមទារថ្លៃសម្ភារៈបំពាក់ ៩១៦៣៥ $ , ទាមទារថ្លៃប្រាក់កក់ ចំនួន ៤៨០០$ គុណនឹង៣ និងបង្គាប់ឲ្យចុងចម្លើយសងជម្ងឺចិត្ត ការខាតបង់ពេលវេលា ការចំណាយផ្សេងៗរួមទាំងការចំណាយទៅលើមេធាវីចំនួន ១០០.០០០$ តើមានលក្ខណៈសមហេតុសមផល ត្រឹមត្រូវតាមច្បាប់ដែរ ឬទេ ?

-បានឃើញ កិច្ចសន្យាជួលផ្ទះ ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១០ រវាងឈ្មោះ[redacted] សុភាព និងឈ្មោះ [redacted] វីនី ។

-បានឃើញ ពាក្យសុំជូនពិនិត្យភស្តុតាង ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២ របស់ឈ្មោះ[redacted] សុភាព ។

-បានឃើញ របាយការណ៍ស្តីពីការបង់ប្រាក់ប្រចាំខែ រវាងឈ្មោះ [redacted] សុភាព និងឈ្មោះ [redacted] វីនី ។

-បានឃើញ លិខិតទទួលធ្វើការងារ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១០ របស់ម្ចាស់ហាង [redacted] វីនី ។

-បានឃើញ លិខិតប្រគល់-ទទួលការងារ ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១០ របស់ម្ចាស់ហាង [redacted] វីនី ។

-បានឃើញ ឯកសារតាងដោយអក្សរ ( ក ) ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២ ។

-បានឃើញ កិច្ចសន្យាព្រមព្រៀង ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០៩ រវាងឈ្មោះ [redacted] សុធារី និង[redacted] សុភា ។

๗-បានឃើញ កំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី១ ចុះថ្ងៃទី ២៧-១២-២០១១ ។

៦-បានឃើញ កំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី២ ចុះថ្ងៃទី ៣០-០១-២០១២ ។

៣៧៤



374

Scanned with CamScanner

# សំអាងហេតុ

១/-តាមកិច្ចសន្យាជួលផ្ទះ ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១០ ឃើញថា : មានឈ្មោះអ្នកស្រី កែវ សុភាព ជាម្ចាស់ផ្ទះ បានធ្វើកិច្ចសន្យាជួលផ្ទះ~~លេខ ៧៣ E០~~ ផ្លូវលេខ ២០០៤ ភូមិតាងួន សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ ឲ្យទៅលោកស្រី [redacted] វីនី ដែលកិច្ចសន្យានេះជួលមានរយៈពេល ០៥ ឆ្នាំ គិតចាប់ពីថ្ងៃទី០១ ខែ ធ្នូ ឆ្នាំ ២០១០ រហូតដល់ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៥ដើម្បីស្នាក់នៅនិងធ្វើអាជីវកម្ម ដោយភាគីអ្នកជួលបានដាក់ប្រាក់កក់ចំនួន ៤៨០០$ ( បួនពាន់ប្រាំបីរយដុល្លាអាមេរិក ) ។ នាពេលទាញហេតុផលផ្ទាល់មាត់នេះ គូភាគីបានសុំលាយកិច្ចសន្យា ដូច្នេះតុលាការសម្រេចរំលាយកិច្ចសន្យានេះតាមការព្រមព្រៀងរបស់គូភាគី ។

២/-យោងសេចក្តីថ្លែងការណ៍របស់គូភាគី បង្ហាញឲ្យឃើញថា លោកស្រី [redacted] សុភាព បានផ្តាច់ទឹកភ្លើងមិនឲ្យលោកស្រី [redacted] វីនី ដំណើរការបានឡើយ ដែលអាជីវកម្មនេះលោកស្រី [redacted] វីនី ដំណើរការអាជីវកម្មរបស់ខ្លួនបានច្រើនខែមកហើយ និងបានបង់ប្រាក់ឈ្នួលផ្ទះជាហូរហែក្នុងមួយខែ ៤០០$ ដូចមានរបាយការណ៍ស្តីពីការបង់ប្រាក់ប្រចាំខែ ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១០ ជាសំអាង ។ ការដែលលោកស្រី [redacted] សុភាព អះអាងថា មូលហេតុដែលខ្លួនបានផ្តាច់ភ្លើងនិងទឹកដោយសារលោកស្រី [redacted] វីនី មិនបានបង់ប្រាក់ឈ្នួលផ្ទះនៅខែដំបូង គឺខែ ធ្នូ ឆ្នាំ ២០១០ នោះ គឺពុំត្រឹមត្រូវទេ ព្រោះថាលោកស្រី [redacted] សុភាព បានទទួលប្រាក់ខែពីលោកស្រី [redacted] វីនី ជារៀងរាល់ខែយ៉ាងទៀងទាត់ ។ ម្យ៉ាងទៀតការផ្តាច់ភ្លើងនិងទឹកនេះ ពុំមានសេចក្តីសម្រេចពីអាជ្ញាធរមានសមត្ថកិច្ចឡើយ ដូចមាននៅក្នុងប្រការ ៨ នៃកិច្ចសន្យា ចែងថា ពេលមានវិវាទកើតឡើង គូភាគីពិគ្រោះយោបល់គ្នាក្នុងឋានៈជាមិត្តភាព ដោយឈរលើស្មារតីគោរពផលប្រយោជន៍គ្នាទៅវិញទៅមក និងបើសិនជាដោះស្រាយគ្នាមិនត្រូវទេ ភាគីទាំងពីរត្រូវបញ្ជូនរឿងនេះមកតុលាការដែលមានសមត្ថកិច្ច តែផ្ទុយទៅវិញលោកស្រី [redacted] សុភាព ពុំបានគោរពតាមកិច្ចសន្យាឡើយ ។

៣/-ចម្លើយសាក្សីឈ្មោះ [redacted] សុខខែម ជាសាក្សីខាងភាគីដើមចោទ ខ្លួនមានមុខងារជាអ្នកគិតលុយនៅក្នុងហាង បញ្ជាក់ថា ក្នុងមួយថ្ងៃបានចំណូល ៨០ ម៉ឺនរៀល ហើយសេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ អះអាងថា មួយថ្ងៃបានចំណូល ១២០០.០០០ រៀល ដូច្នេះចំណុចនេះតុលាការនឹងពិនិត្យពិចារណា ។

៤/-សេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយ សុំច្រានចោលការទាមទាររបស់ដើមចោទ គឺពុំត្រឹមត្រូវទេ ។ រីឯចំណុចដែលលោកមេធាវីលើកឡើងថា សាក្សីឈ្មោះ [redacted] សុខខែម មកបំភ្លឺពុំបានឲ្យស្បថ តែសាក្សីនេះតុលាការអនុញ្ញាតឲ្យឆ្លើយបំភ្លឺបានដោយពុំចាំបាច់ឲ្យស្បថ យោងតាមបញ្ញត្តិមាត្រា ២៣២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

៥/-រូបថត និងឯកសារភស្តុតាង ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២ ដែលធ្វើឡើងដោយដើមចោទឈ្មោះ [redacted] វីនី បានបញ្ជាក់ពីទំហំនៃការខូចខាត មានដូចជា ៖

ការចំណាយលើការងារជំបូល រុះរើជំបូលចាស់-សង់ជំបូលថ្មី , ចំណាយលើការងារចាក់ដីបំពេញមាន ទីតាំងផ្លូវសំណង់ខាងក្នុង , ចំណាយលើសម្ភារសំអាងកាត់សក់បុរស-នារី , ចំណាយលើផលិតផលសំអាង , ចំណាយលើសម្ភារៈសំរាប់លក់អាហារពេលយប់ , ចំណាយលើសម្ភារៈផ្សេងៗ ដែលសរុបចំនួន ៥១.៦៣៥ $ ដោយខ្លួនបានទាមទារប្រាក់ចំនួននេះ ៥១៦៣៥ $ មកវិញ ,ទាមទារប្រាក់ចំណេញ ចំនួន ១២០០.០០០រៀល ក្នុង១ថ្ងៃ គិតចាប់ពីថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១,ទាមទារប្រាក់កក់ចំនួន ៤៨០០ $ × ៣ ,ទាមទារជម្ងឺចិត្ត ការខាតបង់ពេលវេលា ការចំណាយផ្សេងៗរួមទាំងចំណាយសេវាមេធាវីជាប្រាក់ចំនួន ១០០.០០០ $ ដែលការទាមទារនេះមានលក្ខណៈច្រើនពេក ដូច្នេះតុលាការពិនិត្យពិចារណាតាមភាពសមរម្យ ។

៦/-សម្ភារៈដែលដើមចោទបានបំពាក់ជាប់នឹងផ្ទះជួលរបស់ចុងចម្លើយ គប្បីប្រគល់ឲ្យចុងចម្លើយ ។ រីឯសម្ភារៈដែលបានបំពាក់ ដូចជាចលនវត្ថុមួយចំនួនដែលអាចដកយកបានត្រូវប្រគល់ឲ្យដើមចោទវិញ យោងតាមឯកសារការងាររៀបចំ



Scanned with CamScanner

៧-ការទាមទាររបស់មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ សុំឲ្យតុលាការប្រកាសថា សាលក្រមនេះអនុវត្តជាបណ្តោះអាសន្ននោះ តុលាការមិនអនុញ្ញាតឲ្យទេដោយសាររឿងក្តីនេះកំពុងស្ថិតនៅវិវាទគ្នានៅឡើយ ។

៨/-ចុងចម្លើយឈ្មោះ [redacted] សុភាព ជាអ្នកមានកំហុស ដូច្នេះត្រូវទទួលបន្ទុកប្រាក់ប្រដាប់ក្តី យោងតាមមាត្រា ៦៤ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## សម្រេចសេចក្តី

១/-រំលាយកិច្ចសន្យាជួលផ្ទះ ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១០ រវាងឈ្មោះ [redacted] **សុភាព** ជាភាគីម្ចាស់ផ្ទះ និងឈ្មោះ [redacted] **ទវីឌី** ជាភាគីអ្នកជួលផ្ទះ ចោលជាអសារបង់ ។

២/-បង្គាប់ឲ្យចុងចម្លើយឈ្មោ[redacted] **សុភាព** ផ្តល់សំណងឲ្យដើមចោទឈ្មោះ [redacted] **ទវីឌី** ដូចខាងក្រោម ៖

ក-សងថ្លៃចាក់ដី និងជួសជុលផ្ទះចំនួន ៥៦០៧០ $ ( ប្រាំម៉ឺនប្រាំមួយពាន់សូន្យរយចិតសិបដុល្លាអាមេរិក ) ។

ខ-សងថ្លៃខាតបង់អាជីវកម្ម , ថ្លៃប្រាក់កក់ និងសេវាកម្មមេធាវី សរុបចំនួន **១២ ម៉ឺនដុល្លា ( ដប់ពីរម៉ឺនដុល្លារអាមេរិក )** ការទាមទារប្រាក់លើសពីនេះ ត្រូវច្រានចោល ។

គ-ច្រានចោលការទាមទារសុំអនុវត្តបណ្តោះអាសន្នរបស់លោកមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ ។

៣/-ប្រគល់សម្ភារៈឲ្យដើមចោទ តាមរបាយការណ៍រៀបចំទីតាំងសម្រាប់ប្រកបអាជីវកម្ម ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២ របស់ភាគីដើមចោទ តាមចំណុចដូចខាងក្រោម ៖

-សម្ភារៈសំអាង និងសម្ភារៈកាត់សក់បុរស-នារី ( ក្នុងចំណុច គ ) ។

-សម្ភារៈផលិតផលសំអាង ( ក្នុងចំណុច ឃ ) ។

-សម្ភារៈលក់អាហារពេលយប់ ( ក្នុងចំណុច ង ) និង សម្ភារៈផ្សេង ៗ ( ក្នុងចំណុច ច ) ។

៤/-ប្រគល់សម្ភារៈឲ្យចុងចម្លើយ ដែលដើមចោទបានបំពាក់ជាប់ផ្ទះ តាមរបាយការណ៍រៀបចំទីតាំងសម្រាប់ប្រកបអាជីវកម្ម ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២ របស់ភាគីដើមចោទ តាមចំណុចដូចខាងក្រោម ៖

-សម្ភារៈដំបូល , កញ្ចក់ឆ្លុះ និងតុកាត់សក់បុរស-នារី ( ក្នុងចំណុច ក ) ។

-ការចាក់ដីបំពេញលើទីតាំង ផ្លូវ សំណង់ខាងក្នុង ( ក្នុងចំណុច ខ ) ។

៥/-ប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់ចុងចម្លើយ ។

៦/-សាលក្រមនេះបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១២ និងប្រកាសជាសាធារណៈនៅថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១២ ។

**ចៅក្រមប្រឹក្សា** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

ហត្ថលេខា និង [redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**( បានចម្លងត្រឹមត្រូវតាមច្បាប់ដើម )**

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២

**ក្រឡាបញ្ជី**

[redacted]